# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

## របាយការណ៍កិច្ចប្រជុំ
## ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំខែសីហា

**១. ថ្ងៃ ខែ ឆ្នាំ៖** ថ្ងៃអង្គារ ៨រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៤។

**២. ទីកន្លែង៖** នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធអនឡាញ(Zoom)។

**៣. ប្រធាន និងសមាសភាពចូលរួម ៖**

**៣.១-** ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**៣.២-** សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការពាក់ព័ន្ធ ដែលចូលរួមផ្ទាល់ចំនួន៣៥រូប និងតាមប្រព័ន្ធអនឡាញចំនួន៤៩រូប សរុបចំនួន៨៤រូប។

**៤. របៀបវារៈ៖**

**៤.១**-មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

**៤.២**-បទបង្ហាញស្ដីពី ពិនិត្យនូវវឌ្ឍនភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ ក្នុងវិស័យអប់រំ និងការអប់រំចំពោះយុវវ័យក្នុងសាលា។

**៤.៣**- មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**៥. លទ្ធផល ៖**

**៥.១-** ជាកិច្ចចាប់ផ្តើម **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានថ្លែងនូវមតិស្វាគមន៍ដល់ក្រុមការងារនិងអង្គប្រជុំ ដោយបានថ្លែងនូវការកោតសរសើរក្រុមការងារក៏ដូចជាក្រសួង ស្ថាប័ន រាជធានី ខេត្ត ដែលបានប្រឹងប្រែងចូលរួមក្នុងការអនុវត្តការឆ្លើយតបនឹង

មេរោគអេដស៍កន្លងមក ដែលបង្កឱ្យអត្រាប្រេវ៉ាឡង់មេរោគអេដស៍នៅកម្ពុជា បានធ្លាក់ចុះជាបន្តបន្ទាប់មក នៅត្រឹមតែ ០,៥ % នៅឆ្នាំ២០២៣។

**ឯកឧត្តមបណ្ឌិត** ក៏បានបញ្ជាក់រំលឹកឡើងវិញពីការប្រឹងប្រែងចូលរួមក្នុងការឆ្លើយតបនឹងមេរោគអេដស៍ពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ចាប់តាំងពីការរកឃើញមេរោគអេដស៍ជាលើកដំបូងនៅប្រទេសកម្ពុជា នាឆ្នាំ១៩៩១ ដែលទាំងលើផ្នែកបង្ការ ការព្យាបាល និងគាំទ្រ រហូតមកដល់ឆ្នាំ២០២៣នេះ កម្ពុជាសម្រេចបានគោលដៅ ៨៩-៩៨-៩៨។ ការសម្រេចបាននូវលទ្ធផលនេះ គឺដោយសារមានការយកចិត្តទុកដាក់ពីអតីតប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចតេជោ **ហ៊ុន សែន** ដែលបានអំពាវនាវឱ្យមានការចូលរួមជាចរន្តជាតិ តែមួយក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ និងគិតគូរប្រកបដោយគតិបណ្ឌិតរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី ក្នុងការសម្រេចឱ្យបាននូវគោលដៅជាតិ ៩៥-៩៥-៩៥ ទាំងបីក្នុងឆ្នាំ២០២៥ ព្រមទាំងមានការចូលរួមអនុវត្តពីគ្រប់ភាគីពាក់ព័ន្ធ ទាំងផ្នែកជាតិ អន្តរជាតិ និងសង្គមស៊ីវិល ក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃដែលនឹងឈានទៅសម្រេចបានគោលនយោបាយជាតិ៖

១- កាត់បន្ថយការចម្លងថ្មីតិចជាង ១នាក់ក្នុងមួយថ្ងៃ ឬប្រមាណជា ២០០នាក់ក្នុងមួយឆ្នាំ។

២- កាត់បន្ថយការស្លាប់ដោយសារមេរោគអេដស៍ ឱ្យនៅក្រោម ២០០នាក់ក្នុងមួយឆ្នាំ និង៣) លុបបំបាត់ការមាក់ងាយ និងរើសអើង។

**៥.២-** លោកវេជ្ជបណ្ឌិត **យង់ គន្ធារិទ្ធ** អនុប្រធានលេខាធិការដ្ឋានគណៈកម្មាធិការអន្តរក្រសួងស្តីពីសុខភាពសិក្សា(គ.អ.ស.ស) និងជាអនុប្រធាននាយកដ្ឋានសុខភាពសិក្សា ក្រសួងអប់រំ យុវជន និងកីឡា ធ្វើបានបទបង្ហាញ ដែលផ្តោតលើ៖

១- ក្រុមគោលដៅនៃវិស័យអប់រំនៅកម្ពុជា( ឧត្តមសិក្សា មធ្យមសិក្សាទុតិយភូមិ មធ្យមសិក្សាបឋមភូមិ បឋមសិក្សា និងមត្តេយ្យសិក្សា)។

២- ការដាក់បញ្ចូលក្នុងកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស។

៣- ការដាក់បញ្ចូលក្នុងកម្មវិធីសិក្សាតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ។

៤- ការអប់រំផ្សព្វផ្សាយដល់យុវជនតាមគ្រឹះស្ថានសិក្សា។

៥- បរិវត្តកម្មឌីជីថលកម្មវិធីសិក្សា។

៦- បញ្ហាប្រឈម និងដំណោះស្រាយ។

លោកបានបញ្ជាក់ថា ការអប់រំសុខភាព ត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សា (សុខភាពបន្តពូជ និងសុខភាពផ្លូវភេទ ចាប់ពីថ្នាក់ទី៥ ដល់ថ្នាក់ទី១២) ដោយបង្កើតជាក្របខណ្ឌកម្មវិធីសិក្សា បន្ទាប់មកកម្មវិធីសិក្សាលម្អិត ព្រមទាំងបង្កើតសៀវភៅគោលសម្រាប់គ្រូ និងសម្រាប់សិស្ស ដោយបានបែងចែកទៅតាមកម្រិតដូចជា៖ កម្មវិធីសិក្សាសម្រាប់ចំណេះទូទៅ និងកម្មវិធីសិក្សាសម្រាប់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ។ សមាសភាគមុខវិជ្ជា សុខភាពបន្តពូជ និងសុខភាពផ្លូវភេទក្នុងកម្មវិធីសិក្សាចន្លោះពី ១២ម៉ោងទៅ១៤ម៉ោង ក្នុង១ឆ្នាំសិក្សា។ ក្រសួងអបរំ យុវជន និងកីឡា បានបោះពុម្ពសៀវភៅសិក្សាគោលមុខវិជ្ជាអប់រំសុខភាព

ត្រឹមឆ្នាំ២០២៤ សរុបចំនួន ២៦៦.១៣១ក្បាល ដោយប្រើប្រាស់ថវិកាជាតិ និងថវិកាដៃគូ។ ចំណែកគ្រូចំនួន៧.៦៥៤នាក់ ស្រី៤.១៨៦នាក់ ដែលទទួលបានបំប៉នពីការប្រើប្រាស់សៀវភៅសិក្សាគោល មុខវិជ្ជាអប់រំសុខភាពគិតត្រឹមឆ្នាំ២០២៤។ កម្មវិធីសិក្សា អប់រំសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ បានដាក់ចូលបរិវត្តកម្មឌីជីថលកម្មវិធីសិក្សា ដោយបង្កើតជាឯកសារសម្រាប់ផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញ (PDF, YouTube, Facebook, Telegram group, Webpage, Cartoon, App, ...)។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបាន លោកក៏បានលើកពីបញ្ហាប្រឈម និងដំណោះស្រាយមួយចំនួនដូចជា៖

១- សៀវភៅសិក្សាគោលសម្រាប់គ្រូ និងសិស្សបោះពុម្ពកន្លងមកមិនទាន់សមាមាត្រទៅនឹងតម្រូវការប្រើប្រាស់ និងមិនទាន់គ្រប់កម្រិតថ្នាក់សិក្សានៅឡើយទេ ដែលបញ្ហានេះចាំបាច់ត្រូវបោះពុម្ពចែកផ្សាយបន្ថែមតាមលទ្ធភាពថវិកាដែលមាន ក្នុងនោះថវិកាដែលត្រូវការគឺប្រមាណជាង ៥លានដុល្លារអាមេរិក ដើម្បីអាចគ្របដណ្តប់ទូទាំងប្រទេសតាមនិយាមបច្ចុប្បន្ននៃការប្រើប្រាស់សៀវភៅសិក្សាគោល។

២- គ្រូបង្រៀនមុខវិជ្ជាអប់រំសុខភាពនៅមិនទាន់មានទំនុកចិត្តពេញលេញ ក្នុងការបង្រៀនមុខវិជ្ជាថ្មីនេះដល់សិស្សានុសិស្ស ពិសេសប្រធានបទដែលទាក់ទងនឹងសមាសភាគសុខភាពផ្លូវភេទគ្រប់ជ្រុងជ្រោយ (CSE) រួមទាំងប្រធានបទនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ (SOGIESC) ដែលបញ្ហានេះទាមទារនូវការពង្រឹងសមត្ថភាពបន្ថែមដល់គ្រូបង្រៀនគ្រប់កម្រិតថ្នាក់សិក្សា រួមបញ្ចូលទាំងចំណេះដឹងថ្មីៗពី CSE និង SOGIESC ហើយជាមធ្យមការបំប៉នគ្រូម្នាក់ដោយផ្ទាល់ត្រូវចំណាយថវិកាប្រមាណជា ៣០០ដុល្លារអាមេរិក។

៣- ការធ្វើបរិវត្តកម្មឌីជីថលមុខវិជ្ជាអប់រំសុខភាព នៅមិនទាន់បានគ្រប់ដណ្តប់គ្រប់មេរៀនសំខាន់ៗ និងមិនទាន់បានគ្រប់ថ្នាក់នៅឡើយ ដែលបញ្ហានេះទាមទារពង្រីកវិសាលភាពបន្ថែមដែលជាផ្នែកមួយនៃការដោះស្រាយបញ្ហាកង្វះថវិកាដ៏ច្រើនសម្រាប់បំប៉នគ្រូដោយផ្ទាល់ ហើយជាបទពិសោធន៍កន្លងមកសម្រាប់ការថតសកម្មភាពបង្រៀន ១ម៉ោងសិក្សាមួយចប់ត្រូវការថវិកាប្រមាណ៩០០ដុល្លារអាមេរិក។

៤- ការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាអប់រំសុខភាព នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ នៅមិនទាន់បានពេញលេញ ដោយសារគ្រូឧទ្ទេសនាមមិនទាន់បានបំប៉នគ្រប់ៗគ្នា និងសៀវភៅសិក្សាគោលសម្រាប់គ្រូឧទ្ទេសនាម និងសម្រាប់គរុសិស្ស គរុនិស្សិតនៅមិនទាន់បានបោះពុម្ពគ្រប់ប្រភេទគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ដែលបញ្ហានេះត្រូវបន្តពង្រឹងបន្ថែម ទាំងការអភិវឌ្ឍសៀវភៅសិក្សាគោល ការពង្រឹងសមត្ថភាពគ្រូឧទ្ទេសនាម និងការសិក្សាស្រាវជ្រាវផ្សារភ្ជាប់នឹងការអនុវត្ត ដែលថវិកាសម្រាប់ការងារនេះប្រមាណ ១០ ម៉ឺនដុល្លារអាមេរិក។

ជាបន្ត **ឯកឧត្តមបណ្ឌិត** បានអនុញ្ញាតឱ្យមានកិច្ចពិភាក្សា និងផ្តល់យោបល់យ៉ាងផុលផុស និងមានសំណូមពរពីលោកស្រី លីនដា (តំណាងCNPUD) សូមឱ្យមានការផ្សព្វផ្សាយក្នុងសាលា ពេលសាលាមានការជួបជុំជាមួយអាណាព្យាបាល។

ជាចុងក្រោយ **ឯកឧត្តមបណ្ឌិត** បានផ្តល់នូវមតិ និងអនុសាសន៍ដល់កិច្ចប្រជុំដូចខាងក្រោម៖

- ចាប់ផ្តើមផ្សព្វផ្សាយដោយផ្ទាល់ក្នុងកម្រិតមហាវិទ្យាល័យសម្រាប់និស្សិត។
- បណ្តុះបណ្តាលសម្រាប់គ្រូបង្គោលសម្រាប់កម្មវិធីអប់រំសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ។
- តាមការសិក្សាបានបង្ហាញថា នៅមានការមាក់ងាយ និងរើសអើង ចំពោះអ្នកផ្ទុកមេរោគអេដស៍ និងប្រជាជនគន្លឹះ ដូចនេះការបណ្តុះបណ្តាល និងផ្សព្វផ្សាយ ត្រូវបញ្ចូលការអប់រំពីការមាក់ងាយ និងរើសអើង។
- សូមមន្ទីរសុខាភិបាល និងមន្ទីរអប់រំ យុវជន និងកីឡា របស់រាជធានី ខេត្ត សហការចូលរួមអប់រំផ្សព្វផ្សាយនៅតាមគ្រឹះស្ថានអប់រំ និងវិទ្យាល័យ។

ចុងបញ្ចប់ **ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការ ប្រធានអង្គប្រជុំក៏បានបន្ថែមថា ការងារបង្ការ គឺជាយុទ្ធសាស្ត្រចម្បងក្នុងការងារសុខភាពសាធារណៈ ហើយក៏ជាមូលដ្ឋានគ្រឹះក្នុងការឆ្ពោះទៅសម្រេចគោលដៅការគ្របដណ្តប់សុខភាពសកល។ **ឯកឧត្តមបណ្ឌិត** បានជំរុញលើកទឹកចិត្តឱ្យសមាជិកក្រុមប្រឹក្សាបច្ចេកទេស ដែលអនុវត្តផ្ទាល់លើការងារអេដស៍ លើកពីបទពិសោធន៍រួមជាមួយនឹងឧបសគ្គនានា ក្នុងការអនុវត្តការងារប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដើម្បីរកវិធីសាស្ត្រឆ្លើយតបឱ្យបានទាន់ពេល និងមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃពុធ ៩រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៤

**បានពិនិត្យត្រឹមត្រូវ**

អ្នកធ្វើរបាយការណ៍

**ប្រធានអង្គប្រជុំ**

**ប្រធាននាយកដ្ឋាន ទ.ច.ប.ធ**

**ស៊ុំ ផល្លា**

**វេជ្ជ.ហួត សេរីវង្ស**

**បណ្ឌិត ឈិម ឃិនដាវ៉េត**